**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៣១១ អក-៩៨

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការ ខេត្ត ក្រុង**

**សូមជ្រាប។**

***កម្មវត្ថុ:*** ករណីគ្មានមេធាវី ដើម្បីការពារជនក្រីក្រនៅតាមបណ្តា ខេត្ត-ក្រុង ។

ខ្ញុំសូមជម្រាបលោកថា ក្រសួងយុត្តិធម៌ជាញឹកញាប់តែងបានទទួលលិខិតពីតុលាការខេត្ត-ក្រុង ដែលបញ្ជាក់ថា ខ្វះខាតមេធាវីដើម្បីការពារជនក្រីក្រ ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ រីឯពិរុទ្ធជនមួយចំនួនទៀតត្រូវបានឃុំខ្លួនហួសថេរៈវេលាកំណត់នៃច្បាប់ ក៏ព្រោះតែគ្មានមេធាវីជួយការពាររឿងក្តីរបស់ពួកគេ។

អាស្រ័យហេតុនេះ ក្រសួងយុត្តិធម៌ សូមឱ្យលោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង ធ្វើសំណើទៅគណៈមេធាវីដោយភ្ជាប់ទៅជាមួយនូវសេចក្តីបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានឃុំ,សង្កាត់ អំពីស្ថានភាពក្រីក្ររបស់ជនជាប់ចោទមកជាមួយផង ។

ក្រសួងសង្ឃឹមថា លោកនឹងអនុវត្តតាមគោលការណ៍នេះបានយ៉ាងហ្មត់ចត់ដើម្បីពង្រឹងនូវវិស័យច្បាប់ឱ្យកាន់តែល្អប្រសើរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**